ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៧ មស.

ថ្ងៃសៅរ៍ ៤កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

**គណៈកម្មការរៀបចំការប្រឡងប្រជែង** សូមជូនដំណឹងដល់បេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរលើក១ សម្រាប់ការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀនអនុវិទ្យាល័យ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា ឱ្យបានជ្រាបថា បេក្ខជនទាំងអស់ត្រូវចូលរួមការប្រឡង**វិញ្ញាសាសរសេរលើកទី២** ដែលនឹងប្រព្រឹត្តទៅដូចខាងក្រោម៖

**ក-វិញ្ញាសាប្រឡង**

**១-ប្រព័ន្ធបណ្តុះបណ្តាល បរិញ្ញាបត្រ + ១ (កម្រិតបរិញ្ញាបត្រ)៖**

-ឯកទេសគណិតវិទ្យា ឬ រូបវិទ្យា រយៈពេល ២ម៉ោង(១២:៣០នាទី-១៤:៣០នាទី) មេគុណ៣

-ភាសាអង់គ្លេស ឬ ភាសាបារាំង រយៈពេល ២ម៉ោង(១៥:០០នាទី-១៧:០០នាទី) មេគុណ១

**២-ប្រព័ន្ធបណ្តុះបណ្តាល ១២ + ៤ (កម្រិតថ្នាក់ទី១២)៖**

-ឯកទេសគីមីវិទ្យា ឬ ជីវវិទ្យា រយៈពេល ២ម៉ោង (១២:៣០នាទី-១៤:៣០នាទី) មេគុណ៣

-ភាសាអង់គ្លេស ឬ ភាសាបារាំង រយៈពេល ២ម៉ោង(១៥:០០នាទី-១៧:០០នាទី) មេគុណ១

**៣-ប្រព័ន្ធបណ្តុះបណ្តាល ១២ + ២ (កម្រិតថ្នាក់ទី១២)៖**

-មុខវិជ្ជាឯកទេសទី១ រយៈពេល ២ម៉ោង (១២:៣០នាទី-១៤:៣០នាទី) មេគុណ៣

-មុខវិជ្ជាឯកទេសទី២ រយៈពេល ២ម៉ោង (១៥:០០នាទី-១៧:០០នាទី) មេគុណ២

**ខ-សម័យប្រឡង និងមណ្ឌលប្រឡង**

**-សម័យប្រឡង ថ្ងៃសៅរ៍ ទី១៨ ខែឧសភា ឆ្នាំ២០២៤**

**-មណ្ឌលប្រឡង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ៖** ស្ថិតតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

❖ **បញ្ជាក់៖**

**+បេក្ខជនត្រូវមកដល់មណ្ឌលប្រឡងមុន ១ម៉ោង(ម៉ោង១១:៣០នាទី) និងភ្ជាប់មកជាមួយនូវ៖**

-សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឆាយា(ព្រះសង្ឃ) ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច

-ប៊ិកពណ៌ខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។

**+សម្លៀកបំពាក់សមរម្យ៖**

- សម្រាប់ស្ត្រី ៖ សំពត់ពណ៌ខ្មៅ ឬពណ៌ទឹកប៊ិចចាស់ក្រោមជង្គង់ និងអាវពណ៌ស
- សម្រាប់បុរស ៖ ខោជើងវែងពណ៌ខ្មៅ ឬពណ៌ទឹកប៊ិកចាស់ និងអាវពណ៌ស។

ចំពោះការបែងចែកលេខបន្ទប់ លេខតុ និងព័ត៌មានផ្សេងៗ ពាក់ព័ន្ធដំណើរការនៃការប្រឡង នឹងត្រូវប្រកាសផ្សព្វផ្សាយនៅពេលក្រោយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តឱ្យបានមុឺងម៉ាត់។

**គណៈកម្មការរៀបចំការប្រឡងប្រជែង**

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh